00384587



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02/OCT/2009
ម៉ោង (Time/Heure): 08:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Fuy

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី "ឌុច" សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ
ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ -ថ្ងៃជំនុំជម្រះទី ៦៦

រៀបចំដោយ: សែ គុលវុឌ្ឍី និង Natacha WEXELS-RISER

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 02/OCT/2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Fuy

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក Matteo Crippa, លោកស្រី សែ គុលវុឌ្ឍី, កញ្ញា Natacha Wexels-Riser, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Vincent De Wilde D'estmael, លោក សេង ប៊ុនឃាង, លោក ប៉ាក ចន្ទលីណូ, លោកស្រី ជុន សុលក្ខណ៍, លោក ទី មុន្នីន, លោក ហ្លួត វិចិត្រ, លោក ម៉ម ចាន់វណ្ណៈ |

| |
|---|
| ជនជាប់ចោទ៖ លោក កាំង ហ្គេចអ៊ាវ ហៅឌុច |
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ, លោក François Roux(អវត្តមាន), លោកស្រី Marie-Paule Canizares, លោកស្រី Heleyn Unac |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ កញ្ញា Silke Studzinsky, លោកស្រី Fabienne Trusses-Naprous, លោក គីម ម៉េងឃី, លោក Alain Werner, កញ្ញា ទី ស្រីនណា, លោក ហុង គីមសួន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ិច អារុណ |
| ផ្សេងៗ៖ លោកស្រី Maryvonne Maniacky, លោកScott Bywater, លោក Pierre Cozette, លោក សាន គីរី |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ | ចាប់ផ្តើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៦.១៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាក | ចាប់ផ្តើមម៉ោង៖ ១២.០០ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៥ ម៉ោង និង ១៥ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការដកសំណើក្នុងការស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី Jeffrey James (E2/86) និងសំណើក្នុងការផ្លាស់ប្តូរលំដាប់លំដោយនៃដើមបណ្តឹងរដ្ឋប្បវេណីដែលមកធ្វើសេចក្តីថ្លែងការណ៍ | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ និងក្រុមទី២ | ៩.០៧ | ៩.១៣ |
| ការធ្វើសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ស៊ីរ៉ាត់ (D25/6) | ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ | ៩.១៣ | ១១.១៦ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ជុំ ស៊ីរ៉ាត់(D25/6) | សហព្រះរាជអាជ្ញា | ១១.១៦ | ១១.២៤ |

| | | | |
|---|---|---|---|
| ការកត់សម្គាល់របស់ជនជាប់ចោទ | អង្គជំនុំជម្រះ | ១១.៣០ | ១១.៤១ |
| ការធ្វើសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ នៅ (D25/16) | ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី៤ | ១១.៤២ | ១១.៥៩ |
| ការធ្វើសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ូ សាវរិទ្ធិ (E2/26) | ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី៤ | ១៣.៣៨ | ១៥.១៦ |
| ការតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី អ៊ូ សាវរិទ្ធិ (E2/26) | សហព្រះរាជអាជ្ញា | ១៥.១៨ | ១៥.២២ |
| ការធ្វើសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ នៅ (D25/16) | អង្គជំនុំជម្រះ | ១៥.២៨ | ១៦.០០ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការដកសំណើក្នុងការស្ដាប់សេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី** Jeffrey James (E2/86)

មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី១ បានដកសំណើរបស់ខ្លួនក្នុងការស្ដាប់សេចក្ដីថ្លែងការណ៍ដើមបណ្ដឹងរដ្ឋប្បវេណី Jeffrey James។

មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី២ បានស្នើសុំផ្លាស់ប្ដូរលំដាប់លំដោយនៃដើមបណ្ដឹងរដ្ឋប្បវេណីដែលមកធ្វើសេចក្ដីថ្លែងការណ៍។

**ការធ្វើសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ស៊ីរ៉ាត់** (D25/6)

អង្គជំនុំជម្រះបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ស៊ីរ៉ាត់ ។

សហព្រះរាជអាជ្ញាបានតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី។ មេធាវីការពារក្ដីមិនមានសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។

ជនជាប់ចោទបានទទួលស្គាល់សក្ខីកម្ម និងបានផ្ដល់មតិយោបល់ទៅលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

**ការធ្វើសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ នៅ** (D25/16)

អង្គជំនុំជម្រះបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ នៅ។

001/18-07-2007-ECCC/TC
E1/66

សេចក្តីថ្លែងការណ៏របស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកាត់ដោយបញ្ហាបច្ចេកទេសមិនដំណើរការ។

**ការធ្វើសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ សាវរិទ្ធិ** (E2/26)
អង្គជំនុំជម្រះបានស្តាប់សេចក្តីថ្លែងការណ៏របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ សាវរិទ្ធិ តាមរយៈការចូលរួមពីចំងាយ។
សហព្រះរាជអាជ្ញាបានតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីការពារក្តីមិនមានសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧.៣**

| លេខយោងរបស់អជសស | លេខយោងរបស់កសចស | ឈ្មោះ/ការអធិប្បាយ | ចំណាត់ថ្នាក់ឯកសារ (សំងាត់បំផុត,សំងាត់ ឬសាធារណៈ) | កំណត់សម្គាល់ |
|---|---|---|---|---|
| E3/132/1 | គ្មាន | អត្តសញ្ញាណប័ណ្ណជាតិខ្មែរ របស់ ជុំ ស៊ីរ៉ាត់ | សម្ងាត់ | 00371325-00371326 |
| E3/502 | D25/6 | ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ស៊ីរ៉ាត់ រួមមានរូបថតរបស់ ជុំ ស៊ីណារ៉េត | សាធារណៈ កោសលុប | 00194506-00194512 ជាពិសេស 00194512 00194497-00194505 00221949-00221961 កោសលុបពត៍មានបុគ្គល |
| E3/19 | D93/III | ការកត់សម្គាល់របស់ជនជាប់ចោទលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ស៊ីរ៉ាត់ | សាធារណៈ | 00204314-00204322 00208746-00208758 00204301-00204313 មាននៅក្នុងE3រួចហើយ |
| E3/503 | D25/16 | ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ នៅ | សាធារណៈ កោសលុប | 00239751-00239758 00211367-00211378 00249995-00250011 កោសលុបពត៍មានបុគ្គល |
| E3/503/1 | D25/16/1 | ឧបសម្ព័ន្ធ១៖អត្តសញ្ញាណប័ណ្ណជាតិខ្មែររបស់ ជុំ នៅ | សម្ងាត់ | 00234043-00234043 00211379-00211379 |
| E3/503/2 | D25/16/2 | ឧបសម្ព័ន្ធ២៖ ប្រវត្តិរូបអ្នកទោស | សាធារណៈ | 00233371-00233371 00211380-00211380 |

| | | | | |
|---|---|---|---|---|
| | | ជុំ នៅ | | 00289729-00289729 |
| E3/38 ឧបសម្ព័ន្ធក | D55 ឧបសម្ព័ន្ធក | ស២១ បញ្ជីឈ្មោះអ្នកទោស (១៩៧៥-១៩៧៨) | សាធារណៈ | 00171429-00171798 ជាពិសេស 00171629 និង 00171639 មាននៅក្នុងE3រួចហើយ |
| E3/504 | D57 ឧបសម្ព័ន្ធ៥៩ | ឧបសម្ព័ន្ធ៥៩៖បញ្ជីឈ្មោះអ្នកទោសមកពីអង្គភាពសេនាធិការ | សាធារណៈ | 00181653-00181661 ជាពិសេស 00181657 00021162-00021177 |
| E68.9 | គ្មាន | ឧបសម្ព័ន្ធ៩៖ ស២១ បញ្ជីឈ្មោះអ្នកទោសមកពី RAK | សាធារណៈ | 00331262-00331472 ជាពិសេស 00331375 |
| E68.14 | គ្មាន | ឧបសម្ព័ន្ធ១៤៖ស២១បញ្ជីឈ្មោះអ្នកទោសមកពី RAK Center Units | សាធារណៈ | 00331730-00331865 ជាពិសេស 00331803 |
| E68.5 | គ្មាន | ឧបសម្ព័ន្ធ៥៖ ស២១បញ្ជីឈ្មោះអ្នកទោសជាបុរស | សាធារណៈ | 00330944-00331191 ជាពិសេស 00331076 |
| E2/26/5.3 | គ្មាន | ឧបសម្ព័ន្ធ៣៖ រូបថតរបស់ អ៊ូ វិនឌី | សាធារណៈ | 00364944-00364946 00364094-00364095 |
| E2/26/5.2 | គ្មាន | ឧបសម្ព័ន្ធ២៖ អត្តសញ្ញាណប័ណ្ណជាតិខ្មែររបស់ អ៊ូ សាវរិទ្ធិ | សម្ងាត់ | 00364092-00364093 00364941-00364943 |
| E2/26/5.1 | គ្មាន | ឧបសម្ព័ន្ធ១៖ សំបុត្រកំណើតរបស់ អ៊ូ សាវរិទ្ធិ | សម្ងាត់ | 00364089-00364091 |
| E2/31.4 | គ្មាន | ឧបសម្ព័ន្ធ៤៖ ចម្លើយសារភាពរបស់ អ៊ូ វិនឌី | សាធារណៈ | 00274265-00274314 ជាពិសេស 00274308 00274282,00274288 00274216-00274264 ជាពិសេស 00274241 |

| **<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>** |
|---|
| ១-សេចក្តីសម្រេចកែប្រែកាលវិភាគសវនាការ<br>អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីឲ្យបានជ្រាបថា ដោយសារតែដំណើរការនីតិវិធីប្រព្រឹត្តទៅមាន |

ភាពឆាប់រហ័ស និងដោយសារតែមាននូវការបោះបង់សិទ្ធិក្នុងការធ្វើសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនក្នុងរយៈពេលពីរបីថ្ងៃកន្លងមកនេះ  អង្គជំនុំជម្រះបានរៀបចំឡើងវិញនូវកាលវិភាគសវនាការសម្រាប់សប្តាហ៍បន្ទាប់ដូចខាងក្រោម៖

នៅថ្ងៃច័ន្ទ អង្គជំនុំជម្រះនឹងបន្តស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ នៅ ហើយ បន្ទាប់នឹងស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈិន ណារី , តូច មុន្និន និង រស់ មេន ។ បន្ទាប់ពីស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីខាងលើរួចហើយ អង្គជំនុំជម្រះនឹងសម្រាក ។

នៅព្រឹកថ្ងៃអង្គារ  អង្គជំនុំជម្រះនឹងស្តាប់នូវសក្ខីកម្មរបស់អ្នកជំនាញ CP2/5 លើបញ្ហាទាក់ទងនិងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

នៅល្ងាចថ្ងៃអង្គារ  អង្គជំនុំជម្រះនឹងស្តាប់នូវការជំទាស់របស់មេធាវីការពារក្តីចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី  និងស្តាប់នូវការឆ្លើយតបពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះការជំទាស់នោះ ។ អង្គជំនុំជម្រះនឹងស្តាប់នូវការជំទាស់និងការឆ្លើយតបចំពោះការជំទាស់នេះ សម្រាប់រយៈពេលប្រហែលជា ២ ថ្ងៃ។

បន្ទាប់មកអង្គជំនុំជម្រះនឹងចាប់ផ្តើមសួរសំនួរដល់ជនជាប់ចោទទាក់ទងនិងអត្តចារិករបស់គាត់ ។

នៅសប្តាហ៍បន្ទាប់  អង្គជំនុំជម្រះនឹងចាប់ផ្តើមស្តាប់សក្ខីកម្មរបស់អ្នកជំនាញនិងសាក្សីទាក់ទងនិងអត្តចារិករបស់ជនជាប់ចោទ។

អង្គជំនុំជម្រះរក្សាសិទ្ធិក្នុងការកែប្រែកាលវិភាគនេះ  នឹងបន្តធ្វើបច្ចុប្បន្នភាពដល់ភាគីប្រសិនបើការកែប្រែកម្មវិធីត្រូវឲ្យមាន។

២-បង្គាប់ឲ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកសវនាការវិញនៅថ្ងៃច័ន្ទ ទី២៤ ខែសីហា ឆ្នាំ២០០៩ ។

<u>ដីកាសម្រាប់ការលើកវារកាលសវនាការ</u>

ការពន្យាពេលសវនាការ៖ សវនាការនឹងបន្តទៅថ្ងៃច័ន្ទ ទី២៤ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ៩.០០

00384593



| ព្រឹក ។ |
|---|

ភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ កុលឧត្តម្ភី** Natacha WEXELS-RISER